# ទិដ្ឋភាពទូទៅស្តីពីកម្មវិធីផ្តល់ប័ណ្ណរថយន្តក្រុង RIPTA សម្រាប់ព្រឹទ្ធវ័យ និងជនពិការ

## ភស្តុតាងបញ្ជាក់ពីអាយុ

ឯកសារ**ណាមួយ**ខាងក្រោមនេះ ត្រូវបង្ហាញជូនធ្វើជាភស្តុតាងបញ្ជាក់ពីអាយុ ៖

1. ប័ណ្ណ Medicare
2. ប័ណ្ណកំណើត
3. ប័ណ្ណបើកបរ
4. អត្តសញ្ញាណប័ណ្ណរដ្ឋ
5. លិខិតឆ្លងដែន
6. អត្តសញ្ញាណប័ណ្ណអាមេរិក (ប័ណ្ណបៃតង) ឬឯកសារបញ្ជាក់សញ្ជាតិ

## ការបញ្ជាក់ពីពិការភាព

ឯកសារ**ណាមួយ**ខាងក្រោមនេះ ត្រូវបង្ហាញជូនសម្រាប់ជាការបញ្ជាក់ពីពិការភាព ៖

1. ប័ណ្ណ Medicare
2. លិខិតរដ្ឋបាលអតីតយុទ្ធជនដែលមានអត្រាពិការភាពត្រឹម ឬលើសពី70%
3. លិខិតពីនិយោជក ឬក្រុមហ៊ុនធានារ៉ាប់រងលើពិការភាពរបស់និយោជកដែលមានអត្រាពិការភាពត្រឹម ឬលើសពី70%
4. លិខិតបច្ចុប្បន្ន (នៅក្នុងរយៈពេលមួយឆ្នាំមុន) ពីសន្តិសុខសង្គមដែលបង្ហាញថា បុគ្គលនេះកំពុងទទួលបានអត្ថប្រយោជ៍ចំណូលសន្តិសុខបន្ថែម (SSI) ឬពិការភាពសន្តិសុខសង្គម (SSDI) ផ្អែកលើមូលដ្ឋានពិការភាព។ លិខិតនេះ អាចជាលិខិតបញ្ជាក់ពិការភាពសន្តិសុខសង្គមច្បាប់ដើម លិខិតបញ្ជាក់អំពីអត្ថប្រយោជន៍ ឬសេចក្តីជូនដំណឹងពីការកែសម្រួលចំណាយក្នុងការរស់នៅ SSI។

ការបញ្ជាក់ពីពិការភាព ៖ **អក្សរដិត=SSDI ឬ SSI ត្រូវបានទទួលយក** *អក្សរទ្រេត=SSDI ឬ SSI មិនត្រូវបានទទួលយក*

| ធានារ៉ាប់រងលើពិការភាពសន្តិសុខសង្គម (SSDI) | ចំណូលសន្តិសុខបន្ថែម (SSI) |
|---|---|
| • អត្ថប្រយោជន៍ពិការភាពត្រូវបង់ជូន ៖<br>○ **បុគ្គលិកពិការភ្នែក ឬមានពិការភាព**<br>○ *កូនពួកគេដែលមានអាយុក្រោម 18ឆ្នាំ ឬអាយុ 18-19ឆ្នាំ និងកំពុងសិក្សានៅវិទ្យាល័យ (អត្ថប្រយោជន៍សិស្ស)*<br>○ **កុមារដែលមានអាយុលើសពី 18ឆ្នាំប្រសិនបើមានពិការភាព**<br>○ *ប្តី/ប្រពន្ធដែលរស់នៅជាមួយកូនក្នុងបន្ទុក*<br>○ **ប្តី/ប្រពន្ធដែលរស់នៅជាមួយពិការភាព**<br>○ **មនុស្សពេញវ័យពិការពីកុមារភាព** | • អត្ថប្រយោជន៍ SSI ត្រូវបង់ជូន ៖<br>○ បុគ្គលដែលមានអាយុ 65ឆ្នាំ ឬលើសពីនេះ *<br>○ **មនុស្សពេញវ័យដែលមានពិការភាព ឬពិការភ្នែក**<br>○ **កុមារដែលមានពិការភាព ឬពិការភ្នែក**<br>*បុគ្គលដែលមានអាយុលើសពី65ឆ្នាំមានសិទ្ធិទទួលបានសបុត្ររថយន្តក្រុងផ្អែកលើអាយុ។ |

5. លិខិតពីទីភ្នាក់ងារដែលបានអនុម័តបញ្ជាក់ថា អ្នកមានពិការភាព។ បច្ចុប្បន្ន ទីភ្នាក់ងារខាងក្រោមនេះ ត្រូវបានអនុម័តឲ្យផ្តល់លិខិតដល់ RIPTA។ ទីភ្នាក់ងារផ្សេងទៀតដែលអាចនឹងចាប់អារម្មណ៍ក្នុងការផ្តល់លិខិតបញ្ជាក់នឹងត្រូវបានពិចារណាផងដែរ។

- ការិយាល័យសេវាស្តារនីតិសម្បទា (ORS)
- មជ្ឈមណ្ឌលវេជ្ជសាស្ត្រ VA
- Crossroads RI
- សម្ព័ន្ធគាំពារសហគមន៍
- មជ្ឈមណ្ឌល Providence Center
- ឧស្សាហកម្មសុច្ឆន្ទៈរបស់ RI
- សាលាសម្រាប់មនុស្សថ្លង់
- មណ្ឌលរស់នៅដោយឯករាជ្យ PARA (PARI Independent Living Center)
- គម្រោងជំងឺអេដស៍របស់ RI
- គ្រឹះស្ថាន Northern RI Collaborative
- មជ្ឈមណ្ឌលនៃក្តីសង្ឃឹម (House of Hope)
- មណ្ឌលព្យាបាលវិបត្តិពាក្យសម្តី និងការស្តាប់នៃមន្ទីរពេទ្យ RI
- មណ្ឌលរដ្ឋមហាសមុទ្រសម្រាប់ការរស់នៅដោយឯករាជ្យ (Ocean State Center for Independent Living, OSCIL))
- មណ្ឌលសុខភាពផ្លូវចិត្ត Riverwood
- មណ្ឌល Kent Center
- មណ្ឌល Gateway Healthcare

## ភស្តុតាងបញ្ជាក់ពីអត្តសញ្ញាណ

តម្រូវឲ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតដូចជា ប័ណ្ណបើកបរ អត្តសញ្ញាណប័ណ្ណរដ្ឋ លិខិតឆ្លងដែន ឬប័ណ្ណសម្គាល់ខ្លួនសិស្ស។ ប្រសិនបើបុគ្គលនោះ មិនមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេ មាតាបិតា អាណាព្យាបាល សមាជិកគ្រួសារ បុគ្គលិកកាន់ករណី ឬបុគ្គលិកទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតអាចនឹងបង្ហាញប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតរបស់ពួកគេ ហើយធ្វើការធានាដល់អត្តសញ្ញាណរបស់បុគ្គលនោះ។

## ភស្តុតាងបញ្ជាក់ពីចំណូល

ភស្តុតាងបញ្ជាក់ពីអាយុ ឬពិការភាពអាចឲ្យបុគ្គលមានសិទ្ធិទទួលបានប័ណ្ណរថយន្តក្រុងក្នុងតម្លៃពាក់កណ្តាល។ ដើម្បីមានសិទ្ធិទទួលបានប័ណ្ណរថយន្តក្រុងដោយឥតគិតថ្លៃនោះ បុគ្គលត្រូវបំពេញទៅតាមគោលការណ៍ណែនាំស្តីពីចំណូលជាក់លាក់។ មាតាបិតា ឬអាណាព្យាបាលកុមារដែលមានអាយុក្រោម18ឆ្នាំត្រូវបំពេញទៅតាមគោលការណ៍ណែនាំស្តីពីចំណូល ដើម្បីឲ្យគេចេញប័ណ្ណដោយឥតគិតថ្លៃដល់កុមារ។

## <u>គោលការណ៍ណែនាំស្តីពីចំណូលឆ្នាំ2012</u>

លក្ខខណ្ឌតម្រូវនៃចំណូលត្រូវបានកំណត់នៅកម្រិតភាពក្រីក្រសហព័ន្ធ 200%។

ឯកសារ**<u>ណាមួយ</u>**ខាងក្រោមអាចប្រើប្រាស់ជាភស្តុតាងបញ្ជាក់ពីចំណូល។

- ប័ណ្ណជំនួយវេជ្ជសាស្ត្រ (ប័ណ្ណ Medicaid)
- លិខិតបញ្ជាក់សន្តិសុខសង្គមបច្ចុប្បន្ន
- លិខិតបញ្ជាក់ពីរដ្ឋបាលអតីតយុទ្ធជនបច្ចុប្បន្ន

- សំណៅថតចម្លងមូលប្បទានបត្របច្ចុប្បន្ន និង/ឬរបាយការណ៍ធនាគារ និង/ឬរបាយការណ៍សោធននិវត្តន៍
- ប្រតិចារិកគណនីពន្ធអាចទទួលបានពី IRS ជាភស្តុតាងបញ្ជាក់ពីចំណូល។ ប្រសិនបើបុគ្គលណាមួយ មិនមានចំណូល ចាំបាច់ត្រូវមានប្រតិចារិកគណនីពន្ធ។

**<u>ទទួលបានប្រតិចារិកគណនីពន្ធពី IRS</u>** *( ពី irs.gov )*

| តើឯកសារអ្វីខ្លះដែលអ្នកត្រូវការ ? | ប្រមូលព័ត៌មានរបស់អ្នក | ទទួលយកប្រតិចារិករបស់អ្នក |
|---|---|---|
| **ប្រតិចារិកគណនីពន្ធ**<u>ដោយឥតគិតថ្លៃ</u>ផ្តល់នូវព័ត៌មានមូលដ្ឋានរួមមាន ស្ថានភាពគ្រួសារ ប្រភេទនៃចំណូលរក្សាទុក ប្រាក់ចំណូលដុលកែសម្រួល និងចំណូលជាប់ពន្ធ។ | 1. លេខសន្តិសុខសង្គម<br>2. ថ្ងៃខែឆ្នាំកំណើត<br>3. អាសយដ្ឋានផ្លូវ<br>4. លេខប្រៃសណីយ៍ | សូមចូលទៅកាន់ www.irs.gov ឬទូរសព្ទទៅលេខ 1-800-908-9946 ឬទៅកាន់ការិយាល័យ IRS |

**<u>ទីតាំងការិយាល័យ IRS</u>**

| ទីក្រុង | អាសយដ្ឋានផ្លូវ | ម៉ោង/ថ្ងៃធ្វើការ | ទូរសព្ទ |
|---|---|---|---|
| Providence | 380 Westminster St. | ច័ន្ទ-សុក្រ ៖ 8:30ព្រឹក-4:30ល្ងាច | ( 401 ) 525-4282 |
| Warwick | 60 Quaker Lane | ច័ន្ទ-សុក្រ ៖ 8:30ព្រឹក-4:30ល្ងាច | ( 401 ) 826-4797 |

# គោលនយោបាយស្តីពីតម្លៃ

បុគ្គលណាដែលកាន់ប័ណ្ណឥតគិតថ្លៃអាចប្រើប្រាស់សេវាផ្លូវដែលបានកំណត់ទាំងអស់ដោយឥតគិតថ្លៃ។ បុគ្គលណាដែលកាន់ប័ណ្ណមានតម្លៃទាបតម្រូវឲ្យបង់ថ្លៃពាក់កណ្តាលក្នុងម៉ោងមិនសូវមមាញឹក និងបង់ថ្លៃពេញក្នុងម៉ោងមមាញឹកលើគ្រប់សេវាតាមផ្លូវដែលបានកំណត់ទាំងអស់។

**ម៉ោងមមាញឹក ៖**

7ព្រឹក to 9ព្រឹក និង 3ល្ងាច to 6:00ល្ងាចនៅថ្ងៃធ្វើការ។

**ម៉ោងមិនសូវមមាញឹក ៖**

មុនម៉ោង 7ព្រឹកនៅចន្លោះម៉ោង 9ព្រឹក-3ល្ងាច និងក្រោយម៉ោង 6ល្ងាចនៅថ្ងៃធ្វើការ។ គ្រប់ថ្ងៃទាំងអស់នៅថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សំរាក។ ប័ណ្ណរថយន្តក្រុងនឹងបង្ហាញថាតើអ្នកដំណើរត្រូវបានឯកភាពឲ្យអមដំណើរដោយជំនួយការថែទាំផ្ទាល់ខ្លួន ( PCA ) ឬទេ។ PCA ធ្វើដំណើរដោយឥតគិតថ្លៃ។ ភ្ញៀវ ឬអ្នកហែហមផ្សេងទៀតត្រូវតែបង់ថ្លៃធម្មតា។

# ការទទួលយកប័ណ្ណរថយន្តក្រុង

**<u>កន្លែងដែលទទួលបានការឯកភាពសម្រាប់កម្មវិធីផ្តល់ប័ណ្ណរថយន្តក្រុង ៖</u>**

1. ការិយាល័យផ្តល់ប័ណ្ណសម្គាល់របស់ RIPTA ស្ថិតនៅឯ 1 Kennedy Plaza ក្នុង Downtown Providence។ ការិយាល័យបើកទ្វារធ្វើការពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ចាប់ពីម៉ោង 9:00ព្រឹក – 12:00ថ្ងៃត្រង់ និងម៉ោង 1:00ថ្ងៃ - 4:00ល្ងាច។ ការិយាល័យបិទទ្វារនៅថ្ងៃឈប់សម្រាក។

2. ក្រុមចល័ត RIPTA នឹងទៅដល់ទីតាំងដែលស្ថិតនៅក្រៅ Providence នៅថ្ងៃសុក្រ។ សូមមើលគេហទំព័រ RIPTA នៅ www.ripta.com ឬទូរសព្ទទៅកាន់លេខ 784-9500 លេខបន្ត 604 សម្រាប់ទីតាំងនានា។

**តម្លៃ ៖** ថ្លៃប័ណ្ណរថយន្តក្រុងគឺ $25.00។

**កាលបរិច្ឆេទផុតកំណត់ ៖** ប័ណ្ណនេះមានសុពលភាពរយៈពេល 5ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញប័ណ្ណ។

**ការប្តូរប័ណ្ណរថយន្តក្រុង ៖**

- ប័ណ្ណរថយន្តក្រុងដែលខូចខាតត្រូវតែប្រគល់មកវិញដើម្បីទទួលបានប័ណ្ណរថយន្តក្រុងជំនួសមួយទៀត។
- ក្នុងករណីដែលប័ណ្ណរថយន្តក្រុងត្រូវបានបាត់ ឬត្រូវគេលួច ការប្តូរនឹងចេញជូនសាជាថ្មីក្រោយពេលជូនដំណឹងទៅកាន់ RIPTA។
- មានគិតថ្លៃសម្រាប់ប័ណ្ណរថយន្តក្រុងជំនួស។
    - $10.00 សម្រាប់ការប្តូរលើកដំបូង
    - $15.00 សម្រាប់ការប្តូរលើកទីពីរ
    - $20.00 សម្រាប់ការប្តូរលើកទីបី ឬលើកក្រោយៗទៀត

**ការធ្វើប័ណ្ណរថយន្តក្រុងសាជាថ្មី ៖**

- ការធ្វើប័ណ្ណរថយន្តក្រុងសាជាថ្មីមានគិតថ្លៃសេវា។
- ព្រឹទ្ធវ័យអាចធ្វើប័ណ្ណរថយន្តក្រុងសាជាថ្មីរបស់ពួកគាត់បានដោយផ្តល់ជូននូវប័ណ្ណដែលផុតកំណត់ និងភស្តុតាងបញ្ជាក់ពីចំណូល។
- ជនពិការត្រូវផ្តល់នូវការបញ្ជាក់ថ្មីមួយពីពិការភាព និងចំណូល។

**ប័ណ្ណរថយន្តក្រុងដែលបានដកហូតមកវិញ ៖**

រថយន្តក្រុងដែលបានរឹបអូស ឬដកហូត និងយកមកវិញក្រោយពេលស៊ើបអង្កេតមានថ្លៃដំណើរការសេវា $5.00។ RIPTA អាចនឹងសម្រេចលុបចោលថ្លៃដំណើរការនេះ ទៅតាមករណីនីមួយៗអាស្រ័យលើស្ថានភាពជាក់ស្តែង។

## ការប្រើប្រាស់ប័ណ្ណរថយន្តក្រុង RIPTA

ប័ណ្ណរថយន្តក្រុង RIPTA អាចប្រើប្រាស់ចំពោះសេវាផ្លូវកែតម្រូវ និងផ្លូវកំណត់ធម្មតារបស់ RIPTA។ ប័ណ្ណរថយន្តក្រុងត្រូវតែបង្ហាញជូននៅពេលឡើងជិះរថយន្តក្រុង។ ប័ណ្ណនេះ មានលក្ខណៈអេឡិចត្រូនិក ហើយត្រូវចុះឈ្មោះនៅក្នុងប្រអប់គិតថ្លៃដើម្បីឲ្យគេទទួលស្គាល់។

អ្នកបើកបរមានសិទ្ធិផ្ទៀងផ្ទាត់ប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតថាពិតជារបស់អ្នកប្រើប្រាស់។ ប័ណ្ណរថយន្តក្រុងត្រូវតែរក្សាទុកជាកម្មសិទ្ធិរបស់អ្នកទទួលបានសិទ្ធិនៅគ្រប់ពេលប្រើប្រាស់សេវា RIPTA។

## ការប្រើប្រាស់ប័ណ្ណរថយន្តក្រុង RIPTA មិនត្រឹមត្រូវ

RIPTA រក្សាសិទ្ធិរឹបអូស ឬដកហូតប័ណ្ណរថយន្តក្រុងណាដែលប្រើប្រាស់មិនបានត្រឹមត្រូវ។ ការប្រើប្រាស់មិនបានត្រឹមត្រូវរួមមាន ៖

- ការប្រើប្រាស់ប័ណ្ណផុតកំណត់
- ការប្រើប្រាស់ប័ណ្ណរបស់អ្នកដទៃ
- ការធ្វើឲ្យខូចទ្រង់ទ្រាយប័ណ្ណ
- ការចែករំលែក ឬលក់ប័ណ្ណ
- ការទទួលបានប័ណ្ណដោយមិនត្រឹមត្រូវ - ប្រសិនបើគេរកឃើញថា ពាក្យសុំមានលក្ខណៈក្លែងបន្លំក្រោយពេលដែលប័ណ្ណត្រូវបានផ្តល់ជូនរួចហើយនោះ ប័ណ្ណនេះនឹងត្រូវដកហូតមកវិញ។

ប័ណ្ណដែលបានរឹបអូស ឬដកហូតនឹងមិនត្រូវប្រគល់ឲ្យវិញ ឬប្តូរជូនក្នុងអំឡុងពេលមួយឆ្នាំឡើយ។ ក្រោយអំឡុងពេលមួយឆ្នាំ បុគ្គលអាចដាក់ពាក្យសាជាថ្មីទៅកាន់កម្មវិធីផ្តល់ប័ណ្ណរថយន្តក្រុង។

អតិថិជនដែលប័ណ្ណរបស់ពួកគេត្រូវបានរឹបអូសដោយសារតែប្រើប្រាស់ហួសកាលបរិច្ឆេទផុតកំណត់ដោយអចេតនានោះ អាចនឹងធ្វើជូនសាជាថ្មីភ្លាមៗ។

អ្នកដំណើរណាមួយដែលប័ណ្ណពួកគេត្រូវបានរឹបអូស ឬដកហូតនោះ ត្រូវបង់ថ្លៃប្តូរ ឬធ្វើប័ណ្ណថ្មីធម្មតា។ សំបុត្រទាំងឡាយណាដែលដកហូតមកវិញក្រោយពេលការប្រើប្រាស់មិនត្រឹមត្រូវ ត្រូវបានកែសម្រួលនោះ ត្រូវបង់ថ្លៃដំណើរការសេវា អនុលោមទៅតាមកាលកំណត់បង់ថ្លៃសម្រាប់ប័ណ្ណរថយន្តក្រុងរបស់ RIPTA។

## បណ្តឹងឧទ្ធរណ៍

បុគ្គលម្នាក់អាចជ្រើសរើសដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រសិនបើពាក្យសុំរបស់ពួកគេត្រូវបានបដិសេធ ឬប័ណ្ណរបស់ពួកគេត្រូវបានរឹបអូស ដកហូត ឬយកមកវិញនោះ។ ព័ត៌មានបន្ថែម ឬស្ថានភាពបន្ធូរបន្ថយណាមួយអាចផ្តល់ជូនជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយផ្ញើទៅកាន់ ៖

RIPTA<br>ប្រធានផ្នែកសេវាអតិថិជន<br>កម្មវិធីផ្តល់ប័ណ្ណរថយន្តក្រុង<br>705 Elmwood Avenue<br>Providence, RI  02907

ប្រធានផ្នែកសេវាអតិថិជននឹងត្រួតពិនិត្យគ្រប់ព័ត៌មានពាក់ព័ន្ធទាំងអស់ ស៊ើបអង្កេតអង្គហេតុ ប្រឹក្សាជាមួយភាគីផ្សេងៗទៅតាមការចាំបាច់ និងចេញសេចក្តីសម្រេចនៅក្នុងរយៈពេលដប់ប្រាំ (15) ថ្ងៃធ្វើការក្រោយពេលទទួលបានលិខិតបណ្តឹងឧទ្ធរណ៍។

## សំណួរ

រាល់សំណួរ ឬកង្វល់ណាមួយអំពីកម្មវិធីផ្តល់ប័ណ្ណរថយន្តក្រុងរបស់ RIPTA សម្រាប់ព្រឹទ្ធវ័យ និងជនពិការអាចផ្ញើទៅកាន់ប្រធានផ្នែកសេវាអតិថិជន RIPTA តាមរយៈលេខ (401) 784-9500 លេខបន្ត 183 ឬទៅកាន់ជំនួយការអ្នកគ្រប់គ្រងទូទៅសម្រាប់ទំនាក់ទំនងអតិថិជនតាមរយៈលេខ (401) 784-9500 លេខបន្ត140។